៦-ព្រះរាជក្រឹត្យ នស/រកត/០១០៧/០១៥

# ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ (អប្សរា)
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ (អប្សរា)
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ .-**

ត្រូវបានកែសំរួលមាត្រា២ ជំពូកទី១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ "អប្សរា" ដោយលុបត្រង់វាក្យខណ្ឌ :

"ស្នងការពិសេសការពារបេតិកភ័ណ្ឌនៃក្រសួងមហាផ្ទៃ អនុវត្តភារកិច្ចរបស់ខ្លួនក្នុងតំបន់អង្គរ ដោយសហការជាមួយអាជ្ញាធរខេត្តសៀមរាប" ។

មាត្រា២ថ្មី .-

អាជ្ញាធរ " អប្សរា " មានបេសកកម្មគិតគូរ ដឹកនាំការងាររៀបចំ និងអភិវឌ្ឍន៍ទេសចរណ៍ នៃតំបន់ចំនួនប្រាំ ដែលកំណត់នៅក្នុងព្រះរាជក្រឹត្យលេខ ០០១ នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីអំពីការកំណត់ និងការចាត់ចែងតំបន់សៀមរាប អង្គរ ។

ដើម្បីសំរេចទិសដៅនេះ អាជ្ញាធរ " អប្សរា " ព្រមជាមួយក្រសួងពាក់ព័ន្ធ ត្រូវធ្វើជាអាណាព្យាបាលរួមលើគ្រឹះស្ថានទាំងឡាយ ដែលមានភារកិច្ចទទួលខុសត្រូវ ក្នុងការគ្រប់គ្រងរមណីយដ្ឋានទាំងនោះសរុបមាន :

- អភិរក្សដ្ឋានអង្គរ ដែលមានបេសកកម្មថែរក្សា រៀបចំ និងជួសជុលរមណីយដ្ឋានអង្គរដោយធ្វើសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

- ភ្នាក់ងាររៀបចំការអភិវឌ្ឍន៍ទេសចរណ៍អង្គរ ដែលទទួលបន្ទុកអភិវឌ្ឍន៍ និងសំរបសំរួលបណ្តាញទេសចរណ៍ក្នុងតំបន់នេះ ដោយធ្វើសហការជាមួយក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ និងជាមួយអនុគណៈកម្មាធិការខេត្ត រៀបចំទឹកជីនគូបនីយកម្ម និងសំណង់ ។

- ភ្នាក់ងារអភិវឌ្ឍន៍នគូបនីយកម្មទទួលបន្ទុកគិតគូរ និងធ្វើអោយបានសំរេចនូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធនិងឧបរិរចនាសម្ព័ន្ធផ្នែកទេសចរណ៍ក្នុងតំបន់នេះ ក្រោមការត្រួតពិនិត្យផ្ទាល់របស់អាជ្ញាធរ "អប្សរា" សហការជាមួយរដ្ឋបាលខេត្តសៀមរាប និងអនុគណៈកម្មាធិការខេត្តរៀបចំទឹកជីនគូបនីយកម្ម និងសំណង់ ។

- វិទ្យាស្ថានវប្បធម៌ខ្មែរដែលទទួលបន្ទុកបណ្តុះបណ្តាលប្រវត្តិវិទូ បុរាណវត្ថុវិទូ និងភ្នាក់ងារអភិរក្សទទួលបន្ទុកគ្រប់គ្រង និងទ្រទ្រង់រមណីយដ្ឋានអង្គរ ហើយនិងរាំបរងបង្កើនចំណេះដឹងទាំងឡាយនៅក្នុងផ្នែកវប្បធម៌ និងអរិយធម៌ខ្មែរដោយសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

បណ្តាគ្រឹះស្ថានខាងលើនេះ នឹងត្រូវបង្កើតឡើងដោយអនុក្រឹត្យ ។

មាត្រា២ .-

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ .-

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.០៧០១.០១៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៧

លេខ : ៣៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
[stamp and signature]
ប៊ិន ឈិន